**Declassified to Public**
**06 September 2012**

A 94/I

## គោរពជូនលោកសហចៅក្រមស៊ើបអង្កេត

## លោក យូ ប៊ុនឡេង និង លោក Marcel Lemonde

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 05 / 2008
ម៉ោង (Time/Heure): 13:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

*សំណុំរឿងស៊ើបអង្កេត លេខ: 001/**18-07-2007** - អ.វ.ត.ក/ក.ស.ច.ស និង 002/**19-09-2007** - អ.វ.ត.ក/ក.ស.ច.ស*

កម្មវត្ថុ៖ សំណើសុំពិនិត្យមើលឡើងវិញនូវសេចក្តីសម្រេចចិត្តរបស់លោក ចុះកាលបរិច្ឆេទថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៨ និងសំណើសុំមើលសំណុំរឿងនៅក្នុង **Casemap** និង **ZyLAB** ។

លោកសហចៅក្រមស៊ើបអង្កេតជាទីគោរពដ៏ខ្ពង់ខ្ពស់

យើងខ្ញុំឈ្មោះ ការ សាវុត្ថ និង **François Roux** ជាសហមេធាវីរបស់លោក កាំង ហ្កេកអ៊ាវ ហៅ "ឌុច" មានកិត្តិយសសំណូមពរចំពោះលោក សូមមេត្តាពិនិត្យមើលឡើងវិញសំណើរបស់យើងខ្ញុំដែលចុះកាលបរិច្ឆេទនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ ទាក់ទងនឹងកម្មសិក្សាការិនីនៅក្នុងក្រុមការងាររបស់យើងខ្ញុំ គឺ កញ្ញា Lucile Nattiez អាចមានលទ្ធភាពជួបកូនក្តីរបស់យើងខ្ញុំ នៅមជ្ឈមណ្ឌលឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ។

ជាការពិតណាស់ នៅក្នុងសំណើរបស់យើងខ្ញុំខាងលើនេះ យើងខ្ញុំភ្លេចបញ្ជាក់ថា កញ្ញា Lucile Nattiez ដែល នឹងបញ្ចប់កម្មសិក្សា នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ នឹងចូលជួបកូនក្តីរបស់យើងខ្ញុំតែក្នុងករណីមានការអមដំណើរដោយសមាជិកណាម្នាក់របស់ក្រុមការពារក្តីឲ្យលោក កាំង ហ្កេកអ៊ាវ តែប៉ុណ្ណោះ (សហមេធាវី អ្នកពិគ្រោះយោបល់ផ្នែកច្បាប់ ឬ អ្នកគ្រប់គ្រងសំណុំរឿង) ក្នុងនាមជាអ្នកកត់ត្រា។

ម្យ៉ាងទៀត យើងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកសហចៅក្រមដែលអនុញ្ញាតឲ្យកញ្ញា Lucile Nattiez អាចពិគ្រោះសំណុំរឿងលេខ 001/18-07-2007 និង 002/19-09-2007 នៅក្នុង Casemap និង ZyLAB។

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 27 / 05 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

00193586

ឯកសារ A94/I

សូមលោកសហចៅក្រមស៊ើបអង្កេត មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ភ្នំពេញ ថ្ងៃទី ២៧-៥-២០០៨

សម្រាប់សហមេធាវីទាំងពីររូប

មេធាវីម្នាក់ក្នុងចំណោមមេធាវីទាំងពីររូប

ការ សាវុត្ថ

27-5-2008

MARCEL Lemonde

យូ ប៊ុនឡេង